# COVID-19

Khmer | Rev. July 8, 2025

## COVID-19 គឺជាវីរុសកូរ៉ូណាថ្មី។

វាអាចបង្កជំងឺស្រាល ដូចជាផ្ដាសាយ ឬជំងឺធ្ងន់ធ្ងរ ដូចជារលាកសួត។

ការព្យាបាល ឬថ្នាំបង្ការមិនទាន់មានទេ។

**វារីករាលដាលតាមរយៈ ដំណក់ទឹកតូចៗ នៅពេលមនុស្សមានរោគនេះកណ្ដាស់ ក្អក ឬនិយាយ។**



## រោគសញ្ញា



គ្រុនក្ដៅ គ្រុនរងារ ក្អក ដង្ហក់អស់កម្លាំង ឈឺសាច់ដុំ ឈឺក្បាល បាត់បង់រសជាតិ ឬក្លិន ឈឺបំពង់ក តឹងច្រមុះ ឬហៀរសម្បោរ ចង្អោរ ក្អួត រាករូស។

**ប្រសិនបើអ្នកមានរោគសញ្ញាទាំងនេះ សូមទៅធ្វើតេស្ត។ សូមធ្វើការណាត់ជួបជាមួយនឹងអ្នកផ្ដល់សេវាសុខភាពរបស់អ្នក ឬស្វែងរកកន្លែងធ្វើតេស្តតាមរយៈគេហទំព័រ** tpchd.org/gettested។



## ប្រឈមនឹងហានិភ័យខ្ពស់ពីជំងឺធ្ងន់ធ្ងរ



អ្នកមានអាយុ 65 ឡើងទៅ។



រស់នៅក្នុងមណ្ឌលថែទាំ។



មានបញ្ហាសុខភាពជាដើមហេតុ ឬប្រព័ន្ធភាពសុំទន់ខ្សោយ។

## បង្ការការរីករាលដាលនៃជំងឺ COVID-19។




សូមទៅចាក់វ៉ាក់សាំង។



សូមពាក់ម៉ាស់។



សូមសម្រាកនៅផ្ទះ ប្រសិនបើអ្នកឈឺ។

## ការពារសុខភាពរបស់អ្នក។

**សូម្បីតែអ្នកបានចាក់វ៉ាក់សាំងគ្រប់ដូសក៏ដោយ ក៏អ្នកគួរបន្ត៖**



លាងដៃរបស់អ្នកឲ្យញឹកញាប់ជាមួយសាប៊ូ និងទឹកក្ដៅឧណ្ហៗ។ ដុសលាងដៃឲ្យបាន 20 វិនាទី។



ខ្ទប់ក្អក ឬកណ្ដាស់របស់អ្នក។ ប្រើក្រដាសអនាម័យ ឬកែងដៃរបស់អ្នក។




ធ្វើតេស្ត ប្រសិនបើអ្នកបានប៉ះពាល់នឹងអ្នកណាម្នាក់ដែលមានជំងឺកូវីដ-១៩។
៥ ថ្ងៃបន្ទាប់ពីការប៉ះពាល់។



សូមអនុវត្តតាមការណែនាំអំពីការពាក់ម៉ាស់។ អ្នកអាចនឹងត្រូវការពាក់ម៉ាស់នៅក្នុងផ្ទះ និងនៅទីសាធារណៈដែលមានមនុស្សច្រើន។

**សូមស្វែងយល់បន្ថែម និងបន្តតាមដានព័ត៌មានថ្មីៗតាមគេហទំព័រ tpchd.org/coronavirus។**

Tacoma-Pierce County
Health Department
*Healthy People in Healthy Communities*